ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន

លេខ : ១០៣/១១ ស.ម.ក អ.ជ.ប.គ.ញ

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែ កក្កដា ឆ្នាំ ២០១១

# របាយការណ៍

## ស្តីពី

## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែ មិថុនា ឆ្នាំ ២០១១
## និង ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែ កក្កដា ឆ្នាំ ២០១១

(០១/៦/២០១១-៣០/៦/២០១១)

ខែមិថុនាឆ្នាំ២០១១នេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តតាមទិសដៅពហុវិស័យ ដែលបានដាក់ចេញកាលពីខែឧសភាកន្លងទៅ ដើម្បីរួមចំណែកអនុវត្ត "គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព" របស់រាជរដ្ឋាភិបាលកម្ពុជា សំដៅរក្សាបាននូវសន្តិសុខ សណ្តាប់ធ្នាប់សង្គម ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៤នៃរដ្ឋសភា ។ ជាក់ស្តែង សកម្មភាពនិងលទ្ធផលការងារដែលអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានខិតខំអនុវត្តនៅក្នុងខែមិថុនានេះ មានដូចតទៅ :

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

ខែមិថុនាឆ្នាំ២០១១នេះ ពួកឈ្មួញគ្រឿងញៀននៃប្រទេសជិតខាង ដែលមានទំនាក់ទំនងជាមួយពួកឈ្មួញគ្រឿងញៀននៅក្នុងស្រុក បានបន្តធ្វើសកម្មភាពនាំគ្រឿងញៀនប្រភេទមេតំហ្វេតាមីនគ្រាប់ (ភាគច្រើនមានស្លាកសញ្ញា WY) និង មេតំហ្វេតាមីនទឹកកក (ICE) តាមច្រករបៀងនៃខេត្តស្ទឹងត្រែង និង ខេត្តព្រះវិហារ ចូលមកក្នុងប្រទេសកម្ពុជា ហើយធ្វើការចរាចរចែកចាយទៅតាមបណ្តាខេត្តមួយចំនួន និងមួយចំនួនទៀតបាននាំទៅកាន់តំបន់ព្រំដែនវិញ ជាពិសេសគឺតំបន់ព្រំដែនទិសពាយ័ព្យប្រទេស ។ ជាក់ស្តែង នៅក្នុងខែមិថុនានេះ អង្គភាពអនុវត្តច្បាប់នៅទិសខេត្តស្ទឹងត្រែង និង ខេត្តព្រះវិហារ បានស្រាវជ្រាវរកឃើញនិងបង្ក្រាបបាន ២ ករណី និងចាប់យកមេតំហ្វេតាមីនគ្រាប់ក្នុងចំនួនគួរកត់សំគាល់ ។

ដោយឡែក ពួកឧក្រិដ្ឋជនគ្រឿងញៀនឆ្លងដែនអន្តរជាតិមានអង្គការចាត់តាំង បានប្រើប្រាស់ស្ត្រីជនជាតិហ្វីលីពីន ឱ្យនាំគ្រឿងញៀនប្រភេទកូកាអ៊ីន ពីទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ឆ្លងកាត់ប្រទេសកម្ពុជា តាមច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ក្នុងទិសដៅនាំទៅកាន់ប្រទេសទី៣ ប៉ុន្តែត្រូវមន្ទីរប្រឆាំងគ្រឿងញៀនធ្វើការស្ទាក់ចាប់បានទាន់ពេលវេលា ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

ក្នុងខែមិថុនាឆ្នាំ២០១១ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់លើកកម្ពស់យុទ្ធសាស្ត្រពហុវិស័យ នៃផែនការសកម្មភាពជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន មានដូចខាងក្រោម :

១- ការដឹកនាំសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១០ និងលើកទិសដៅការងារ ឆ្នាំ២០១១ (៣១/៥-០១/៦/២០១១) ។

២- ការស្នើសុំគោលការណ៍សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងស្នើសុំ សារលិខិត របស់សម្តេចផ្ញើជូនបងប្អូនជនរួមជាតិនៅក្នុងឱកាសនៃទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៣- ការដឹកនាំផ្ទាល់ដោយ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ដើម្បីប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននៅខេត្តបន្ទាយមានជ័យ (ក្រុងប៉ោយប៉ែត ស្រុកថ្មពួក) និងការណែនាំឱ្យគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនគ្រប់រាជធានី-ខេត្ត រៀបចំប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៤- ការស្នើសុំគោលការណ៍ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីឱ្យក្រសួងមហាផ្ទៃ រៀបចំនិងដឹកនាំគណៈកម្មការចម្រុះដោះស្រាយបញ្ហាគ្រឿងញៀននៅខេត្តជាប់ព្រំដែនឡាវ ។

៥- ការជំរុញឱ្យក្រសួងសុខាភិបាល អនុវត្តតាមចំណាររបស់សម្តេចនាយករដ្ឋមន្ត្រី ស្តីពីការរៀបចំឱ្យមានសេវាព្យាបាលតាមសហគមន៍ លើគោលដៅ២០% នៃឃុំ-សង្កាត់ គោលដៅសរុប ។

### *១.ការកាត់បន្ថយតម្រូវការគ្រឿងញៀន*

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដឹកនាំនិងសហការសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ធ្វើការផ្សព្វផ្សាយអប់រំ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីច្បាប់, គ្រោះថ្នាក់នៃគ្រឿងញៀន និងមេរោគអេដស៍/ជំងឺអេដស៍ តាមរយៈសកម្មភាពជាច្រើន ក្នុងនោះ ៖

***-អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ :***

-បានចូលរួមជាវាគ្មិន ដើម្បីផ្តល់បទសម្ភាសន៍ និង ធ្វើបទឧទ្ទេសនាម ក្នុងវគ្គបណ្តុះបណ្តាល ជាទូទៅស្តីពីបញ្ហាគ្រឿងញៀន/អេដស៍ នៅសកលវិទ្យាល័យ ជា ស៊ីម កំចាយមារ ខេត្តព្រៃវែង (អ្នកចូលរួម **៣៥០** នាក់) / នៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិង វិទ្យាសាស្ត្រសេដ្ឋកិច្ច (អ្នកចូលរួម **៣០០** នាក់ / នៅខេត្តស្វាយរៀង (អ្នកចូលរួម **១៨៤** នាក់) / នៅក្នុងកម្មវិធី **សមធម៌** និងកម្មវិធី **អរុណសួស្តី** នៃទូរទស្សន៍ជាតិកម្ពុជា / ការចូលរួមជាអធិបតី និងជាកិត្តិយសដោយថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នៅក្នុងទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តស្ទឹងត្រែង ខេត្ត កំពង់ចាម និង ខេត្តព្រះសីហនុ / ការផ្តល់ឯកសារផ្សព្វផ្សាយអប់រំជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីចុះធ្វើសកម្មភាពផ្សព្វផ្សាយអប់រំ ទប់ស្កាត់កុមារ និងយុវជននៅតាមសាលារៀន និងសហគមន៍អាទិភាព ។ល។និង ។ល។

**-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា :**

. បានផ្តល់កិច្ចសម្ភាសន៍នៅស្ថានីយទូរទស្សន៍ស៊ីធីអិន-អ៊ីនធឺណេត ក្រោមប្រធានបទស្តីពីការទទួលខុសត្រូវរបស់ក្រសួង ស.អ.យ ក្នុងការផ្សព្វផ្សាយអប់រំកែប្រែនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

. បានចុះធ្វើសកម្មភាពផ្សព្វផ្សាយអប់រំ ទប់ស្កាត់កុមារ និងយុវជននៅតាមសសាលារៀន និងសហគមន៍អាទិភាព ដែល

មានអ្នកចូលរួមចំនួន **៥០០** នាក់ ។

-**ក្រសួងព័ត៌មាន** ផ្សព្វផ្សាយសារលិខិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ផ្ញើជូនបងប្អូនជនរួមជាតិក្នុងឱកាសអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១១ ។

-**ក្រសួងទេសចរណ៍ :** បានផលិតខិត្តបណ្ណ័អន្តរក្រសួងផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀន / អេដស៍ / អំពើជួញដូរភេទ / ការជួញដូរអាវុធជាតិផ្ទុះ ។

លទ្ធផលជារួម ទាំងលទ្ធផលការងារផ្សព្វផ្សាយអប់រំប្រចាំខែរបស់ក្រសួង-ស្ថាប័ននិងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត និងលទ្ធផលនៃការប្រារព្ធពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (២៦ មិថុនា ២០១១) មានមន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស អាជីវករ ប្រជាពលរដ្ឋ ចូលរួមសរុប **៥៤.៥៤៥** នាក់ (ដូចមានរាយលំអិតនៅក្នុងទំព័រទី១១) ។ ចំនួននេះ ប្រៀបធៀបខែឧសភាឆ្នាំ២០១១កន្លងទៅ(អ្នកចូលរួម ២៩៩៨០ នាក់) គឺមាន ការកើនឡើង ៧៦,៦៩ % និងនៅខ្វះខេត្តពោធិ៍សាត់ ដែលមិនទាន់បានផ្តល់របាយការណ៍ ។

### ***២.ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន***

ខែមិថុនានេះ មន្ត្រីអនុវត្តច្បាប់គ្រប់សមាសភាព និង គ្រប់លំដាប់ថ្នាក់ បានបើកកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀនទទួលបានលទ្ធផលដូចខាងក្រោម :

- ***បង្ក្រាបបទល្មើសគ្រឿងញៀន*** បាន ***៧៩ ករណី*** ប្រៀបធៀបខែឧសភាឆ្នាំ២០១១(បទល្មើសមាន **១៦២** ករណី) គឺថយចុះ ៥១,២៣ % ។
- ***ឃាត់ខ្លួនមនុស្ស ១៦៩ នាក់*** (ប្រុស១៣៩នាក់, ស្រី៣០នាក់) ប្រៀបធៀបខែឧសភាឆ្នាំ២០១១ (ឃាត់ខ្លួនមនុស្ស ៤០៩ នាក់) គឺថយចុះ ៥៨,៦៧% ។ ក្នុងចំនួនមនុស្សដែលបានឃាត់ខ្លួនទាំង ១៦៩ នាក់ នេះមាន : ជនជាតិខ្មែរ - វៀតណាម - ឡាវ - ហ្វីលីពីន - ចិន - បារាំង - ណៅរ៉ាដា (ដូចមានរាយលំអិតនៅក្នុងទំព័រទី១២) ។
- ***វត្ថុតាងចាប់យក*** រួមមាន :

-មេតំហ្វេតាមីនWY ៤៣.១៩៧ គ្រាប់ + ៤,១ ក្រាម - មេតំហ្វេតាមីនICE ៣៨២,៧៧ ក្រាម

-ហេរ៉ូអ៊ីន ២៨២,៤១ ក្រាម -កូកាអ៊ីន ២៦៧,៧ ក្រាម

-អ៊ិចស្តាស៊ី ១.៣៦៣ គ្រាប់ -សារធាតុគីមីផ្សំ ២៩.៥៩១,៨១ ក្រាម

-ដើមកញ្ឆា ៥០០ ដើម -កញ្ឆាក្រៀម ៦១,៥០ ក្រាម

រួមទាំងវត្ថុតាងរួមផ្សំមួយចំនួនទៀត (មានរាយលំអិតនៅក្នុង ទំព័រទី១២ និង ទី១៣) ។

- ***មន្ទីរពិសោធន៍គ្រឿងញៀន*** នៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងសង្ស័យគ្រឿងញៀន នៅក្នុងខែមិថុនាឆ្នាំ២០១១ នេះ សរុបបានចំនួន ១៣១ សំណាក (សំណាក អវិជ្ជមាន ១៥ សំណាក = ១១ % និងសំណាក វិជ្ជមាន ១១៦ សំណាក = ៨៩ % ដែលក្នុងនោះមាន ៖

. មេតំហ្វេតាមីនគ្រាប់ ២៥ សំណាក = ១៩ % . ហេរ៉ូអ៊ីន ៦ សំណាក = ៥ % . កញ្ឆា ៤ សំណាក = ៣ %

. មេតំហ្វេតាមីនម្សៅ ៧១ សំណាក = ៩៤ %  . កេតាមីន ៤ សំណាក = ៣ %

. ផ្សិដូ-អេហ្វេឌ្រីន ៤ សំណាក = ៣ %  . អាស៊ីតស៊ុលហ្វួរិច ២ សំណាក = ២ %

**-ការដុតបំផ្លាញគ្រឿងញៀនតាមសាលក្រមតុលាការ**

នៅក្នុងពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រាជធានីភ្នំពេញ ខេត្តប៉ៃលិន ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តកំពង់ចាម បានធ្វើការដុតបំផ្លាញគ្រឿងញៀន មានដូចតទៅ ហេរ៉ូអ៊ីន ១៣,០៦៨ គ.ក្រ, មេតំហ្វេតាមីនគ្រាប់ (WY) ២៥៣.៣៦៩ គ្រាប់, មេតំហ្វេតាមីន ICE ៦,៣៧៩ គ.ក្រ, ថ្នាំញៀនចម្រុះ ៥៨.៥៤៤ គ្រាប់, ម្សៅខេតាមីន 0,៣១ ក្រាម, កញ្ឆាក្រៀម ៥,២៦៥ គ.ក្រ, អ៊ិចស្តាស៊ី ២៩,៩៩ ក្រាម, សារធាតុគីមីផ្សំគ្រឿងញៀន ៤,៧២៦ គ.ក្រ និងឧបករណ៍ផលិត ប្រើប្រាស់ វេចខ្ចប់មួយចំនួន (មានរាយលំអិតនៅក្នុងទំព័រទី១១) ។

**-ការគ្រប់គ្រងសារធាតុគីមីផ្សំ**

ខែមិថុនានេះ សារធាតុគីមីផ្សំដែលមានច្បាប់អនុញ្ញាតឱ្យនាំចូលដោយក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) សរុបមានចំនួន 799.150 គីឡូក្រាម (ដូចតារាងលំអិតក្នុងទំព័រទី១៣) ។

### ៣.ការព្យាបាល ស្តារនីតិសម្បទា និងការកាត់បន្ថយគ្រោះថ្នាក់

អនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបើកកិច្ចប្រជុំផ្ទៃក្នុងដើម្បី ពិនិត្យលើផែនការអភិវឌ្ឍន៍សេវាសុខភាពផ្លូវចិត្ត និង គ្រឿងញៀន របស់ក្រសួងសុខាភិបាល ក្រោមការដឹកនាំរបស់ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ ដែលមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម អេង ហួត រដ្ឋលេខាធិការ ក្រសួងសុខាភិបាល ឯកឧត្តម លី គឹមឡុង អគ្គលេខាធិការរង និងក្រុមការងារ ដើម្បីពិនិត្យពិភាក្សាលើកិច្ចដំណើរការរៀបចំសេវាថែទាំ ព្យាបាលអ្នកញៀនគ្រឿងញៀនផ្អែកលើសហគមន៍ ។ យោងតាមស្មារតីនេះ ក្រុមការងារបានរៀបចំ"ផែនការអភិវឌ្ឍន៍ សុខភាពផ្លូវចិត្ត និង គ្រឿងញៀន" និងបានឯកភាពគ្នាជ្រើសរើសយកខេត្តអាទិភាព - ចំនួនមន្ទីរពេទ្យ - ចំនួនមណ្ឌលសុខភាព ដែលត្រូវបម្រើសេវាថែទាំនិងព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ សរុបចំនួន ៩៨ កន្លែង គឺប្រហែល ២០% នៃចំនួនមណ្ឌលសុខភាព និងមន្ទីរពេទ្យអាទិភាព លើចំនួនរួម ៤៣៥ កន្លែង ដែលបានស្រង់កន្លងមក ។ មន្ទីរពេទ្យ និងមណ្ឌលសុខភាពចំនួន ៩៨ នេះ នឹងយកទៅធ្វើការពិភាក្សាជាមួយក្រសួងសុខាភិបាល ដើម្បីដំណើរការកម្មវិធីព្យាបាលដោយផ្អែកលើសហគមន៍ ។

ដោយឡែក ក្រសួងសុខាភិបាល បានចាត់ថ្នាក់ដឹកនាំក្រសួង១រូប (ថ្នាក់រដ្ឋលេខាធិការ) ដើម្បីចូលរួមរៀបចំយន្តការលើការរៀបចំឱ្យមានសេវាព្យាបាលតាមសហគមន៍សម្រាប់អ្នកញៀនគ្រឿងញៀន និងបានកសាងផែនការយុទ្ធសាស្ត្រ សុខភាពផ្លូវចិត្ត និង គ្រឿងញៀន សម្រាប់ការអនុវត្តន៍ ។

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ តាមការអញ្ជើញរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានចាត់មន្ត្រីជំនាញចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីការរៀបចំរបាយការណ៍លើភាពជាម្ចាស់ការក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍/ជំងឺអេដស៍ នៅប្រទេសកម្ពុជា កាលពីថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១១ នៅសណ្ឋាគារណាហ្គាវើល និងចូលរួមក្នុងកិច្ចប្រជុំការងាររួម រវាងរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ អំពីការងារមេរោគអេដស៍/ជំងឺអេដស៍ (ថ្ងៃទី៣១ ខែ ឧសភា ឆ្នាំ ២០១១) ។ កិច្ចប្រជុំមានការចូលរួមពី

តំណាង អ.ជ.ប.គ.ញ, ក្រសួងសង្គមកិច្ច, ក្រសួងការពារជាតិ, ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ, ក្រសួងអប់រំយុវជននិងកីឡា, ក្រសួងប្រៃសណីយ៍, ក្រសួងទេសចរណ៍, ក្រសួងអភិវឌ្ឍន៍ជនបទ, ក្រសួងព័ត៌មាន, ក្រសួងសុខាភិបាល, ក្រសួងកិច្ចការនារី, ក្រសួងផែនការ, អង្គការ USCDC, NAA, HACC, NCHARDS, UNESCO, CCW, World food Program, JICA, BC, PSI, CPN+, CCW និងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ សរុបប្រមាណ ៣៥ នាក់ ដើម្បី :

១. ពិនិត្យ និងអនុម័តទៅលើរបាយការណ៍នៃកិច្ចប្រជុំកន្លងទៅ

២. ការកៀរគរថវិកាកំណត់សូចនាករសម្រាប់សេវាសកល ២០១៣-២០១៥

៣. ការកៀរគរថវិកាសម្រាប់បោះពុម្ពសៀវភៅយុទ្ធសាស្ត្រគាំទ្រសេវាសកល

៤. រកធនធានសម្រាប់កំណែយុទ្ធសាស្ត្រជាតិបង្ការមេរោគអេដស៍ ក្នុងចំណោមអ្នកងាយប្រឈម

៥. ដំណើរការអភិវឌ្ឍន៍មូលនិធិសកល ជុំទី១១

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ តាមការអញ្ជើញរបស់ក្រសួងអប់រំយុវជននិងកីឡា បានចាត់មន្ត្រីជំនាញទៅចូល រួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការកំណត់ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងវិស័យអប់រំពីឆ្នាំ២០១១ ដល់ ឆ្នាំ២០១៣ កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១១ នៅសណ្ឋាគារ Imperial Garden ភ្នំពេញ ។

ជាមួយបណ្តាប្រទេសក្នុងតំបន់ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចាត់តាំងមន្ត្រីជំនាញរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ២រូប និងសម្របសម្រួលជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីបញ្ជូនមន្ត្រីជំនាញ ១ រូប ទៅចូលរួមក្នុងសិក្ខាសាលាថ្នាក់តំបន់ ស្តីពីគ្រឿងញៀន និងមេរោគអេដស៍ នៅទីក្រុងហាណូយ ប្រទេសវៀតណាម កាលពីថ្ងៃទី១៤-១៧ ខែមិថុនា ឆ្នាំ២០១១ ក្នុងគោលបំណងផ្តល់នូវសេចក្តីសរុបនៃអ្នកប្រើប្រាស់គ្រឿងញៀនដោយការចាក់, ផ្សព្វផ្សាយការអនុវត្តន៍ច្បាប់ សុខភាព និងអនុវត្តច្បាប់ព្រហ្មទណ្ឌ តុលាការ ដើម្បីឈានទៅរកការបង្កើតគោលការណ៍ច្បាប់និងប្រតិបត្តិការបង្ការ មេរោគអេដស៍, ផ្លាស់ប្តូរបទពិសោធន៍ និងចំណេះដឹងក្នុងការអនុវត្តន៍ការព្យាបាលអ្នកញៀនគ្រឿងញៀន និងបង្ការមេរោគអេដស៍ ។

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចាត់មន្ត្រីជំនាញរបស់អគ្គលេខាធិការ ចំនួន ៣ រូប ទៅចូលរួមវេទិកាសម្របសម្រួលនិងទំនាក់ទំនងកម្មវិធី HAARP ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៧-២៩ ខែមិថុនា ឆ្នាំ២០១១ នៅទីក្រុងហ្លួងប្រាបាង ប្រទេសឡាវ ។ សម្រាប់ប្រទេសកម្ពុជា បន្ទាប់ពីការពិនិត្យលទ្ធផលពាក់កណ្តាលគម្រោង បញ្ហាដែលត្រូវអនុវត្តបន្តគឺ :

១. HAARP នឹងបន្តអនុវត្តកម្មវិធីម្ជុល-ស៊ីរ៉ាំង នៅកម្ពុជារហូតដល់ ឆ្នាំ ២០១៥ ។

២. HAARP នឹងអនុវត្តគម្រោងកាត់បន្ថយការឆ្លងរីករាលដាលមេរោគអេដស៍-ជំងឺអេដស៍ ក្នុងចំណោមអ្នកប្រើប្រាស់គ្រឿងញៀននៅកម្ពុជា រហូតដល់ ឆ្នាំ២០១៥ ។

៣. HAARP នឹងបន្តយុទ្ធសាស្ត្រដើម្បីធានាបាននូវនិរន្តរភាពស្របតាមកម្មវត្ថុទាំងបីគឺ ១. ការផ្តល់សេវា ២. ការបង្កើនសមត្ថភាពមន្ត្រីជំនាញ ៣. ការបង្កើតបរិយាកាសងាយស្រួលដល់ការអនុវត្តន៍គម្រោងកម្មវិធីកាត់បន្ថយគ្រោះថ្នាក់គ្រឿងញៀន ដោយយកចិត្តទុកដាក់លើលទ្ធផលជាក់ស្តែង ជាជាងទិន្នផល ។

៤. HAARP នឹងបន្តជំរុញកិច្ចការរបស់ខ្លួន ស្របតាមកម្មវត្ថុទាំងបីរបស់គម្រោង ។

៥. ការប្រមូលព័ត៌មាន ទិន្នន័យគ្រឿងញៀន ដោយផ្អែកលើភស្តុតាងជាមូលដ្ឋាន ។

៦. ការប្រើប្រាស់ព័ត៌មាន ទិន្នន័យគ្រឿងញៀន ឱ្យបានច្បាស់លាស់តាមបែបវិទ្យាសាស្ត្រ ។

៧. HAARP នឹងធ្វើការពិនិត្យកែសម្រួលនូវប្រព័ន្ធតាមដាននិងវាយតម្លៃរបស់ខ្លួន ដោយដាក់បញ្ចូលសូចនាករ សម្រាប់វាយតម្លៃលើទិន្នផល ។

### ៤.ការពង្រឹងសមត្ថភាពការងារអនុវត្តច្បាប់

ដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនូវសមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់កម្ពុជា អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ បាន :

-រៀបចំក្រុមការងារមួយក្រុម សម្រាប់ការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន និងការកាត់បន្ថយគ្រោះថ្នាក់" នៅខេត្តកំពង់ចាម ខេត្តពោធិ៍សាត់ និង ខេត្តឧត្តរមានជ័យ និងបានចុះទៅធ្វើការបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់នៅខេត្តកំពង់ចាម បានចំនួន ១១០ នាក់ កាលពីថ្ងៃទី១៥-១៧ ខែមិថុនា ឆ្នាំ២០១១ ។

-បានធ្វើការសិក្សា ដើម្បីរៀបចំកែសម្រួលតួនាទី ភារកិច្ច សមាសភាព និងត្រួតពិនិត្យសម្ភារៈបរិក្ខារ នៅការិយាល័យទំនាក់ទំនងព្រំដែន (BLO) ចំនួន១៤កន្លែង តាមបណ្តោយព្រំដែន កម្ពុជា-វៀតណាម កម្ពុជា-ឡាវ និង កម្ពុជា-ថៃ ។

### ៥.កិច្ចសហប្រតិបត្តិការអន្តរជាតិ

ដើម្បីពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគី ជាមួយបណ្តាប្រទេសនៅក្នុងតំបន់ និង អន្តរជាតិ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចូលរួមក្នុងសកម្មភាពជាច្រើន រួមមាន :

១- វគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន លើកទី១១ នៅប្រទេសសឹង្ហបុរីពីថ្ងៃទី២៣-២៧ ខែឧសភាឆ្នាំ២០១១ ដែលរៀបចំឡើងក្រោមកិច្ចសហការរវាងប៉ូលីសសហព័ន្ធអូស្ត្រាលី ជាមួយការិយាល័យកណ្តាលកិច្ចការគ្រឿងញៀននៃប្រទេសសឹង្ហបុរីក្នុងក្របខណ្ឌនៃកម្មវិធី ASEAN Training Awards លើប្រធានបទ "បញ្ហាប្រឈមក្នុងការត្រួតពិនិត្យគ្រឿងញៀនខុសច្បាប់ជាលក្ខណៈអន្តរជាតិ" ។ កម្មវត្ថុនៃវគ្គបណ្តុះបណ្តាល រួមមាន ១). ដំណោះស្រាយនិងយុទ្ធសាស្ត្រទប់ស្កាត់ការប្រើបំពានគ្រឿងញៀនរបស់ប្រទេសសឹង្ហបុរី ទី២).សារៈសំខាន់របស់យុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងគ្រឿងញៀនគឺជាវិធានការចាំបាច់ឆ្លើយតបទៅនឹងការប្រើបំពានគ្រឿងញៀន រួមទាំងកិច្ចការអប់រំបង្ការ ការងារអនុវត្តច្បាប់ ការព្យាបាលនិងស្តារនីតិសម្បទា ការថែទាំបន្ត ទី៣).បញ្ហាប្រឈមនានារបស់មន្ត្រីអនុវត្តច្បាប់ និងសារៈសំខាន់នៃកិច្ចសហប្រតិបត្តិការលើការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ទី៤).យុទ្ធសាស្ត្ររបស់ប្រទេសអូស្ត្រាលីក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិអាចជាគន្លឹះក្នុងការកាត់ផ្តាច់ប្រភពចរាចរគ្រឿងញៀន ។

២- សិក្ខាសាលាស្តីពីគ្រឿងញៀននិងអេដស៍/ហ៊ីវ កាលពីថ្ងៃទី១៤-១៨ខែមិថុនាឆ្នាំ២០១១ នៅទីក្រុងហាណូយប្រទេសវៀតណាម( លទ្ធផលមាននៅក្នុងការងារព្យាបាល ស្តារនីតិសម្បទា និងការកាត់បន្ថយគ្រោះថ្នាក់) ។

៣- កិច្ចប្រជុំប្រចាំឆ្នាំ ថ្នាក់មន្ត្រីជាន់ខ្ពស់ និង ថ្នាក់រដ្ឋមន្ត្រី នៃប្រទេសហត្ថលេខីលើអនុស្សារណៈនៃការយោគយល់គ្នា ឆ្នាំ១៩៩៣ (MOU) ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនថ្ងៃទី២២-២៥ ខែឧសភា ឆ្នាំ២០១១ នៅទីក្រុងវៀងច័ន្ទ ប្រទេសឡាវ ដែលត្រូវបានចែកចេញជា ៣ ផ្នែក សំខាន់ៗ :

-កិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ ដើម្បីពិនិត្យ ពិភាក្សា និងវាយតម្លៃឡើងវិញនូវលទ្ធផលនៃការអនុវត្តផែនការសកម្មភាពអនុតំបន់ លើកទី៧ និងសេចក្តីព្រាងផែនការសកម្មភាពអនុតំបន់ថ្មី លើកទី៨ ។

-កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រី បានពិនិត្យនិងអនុម័តជាផ្លូវការលើឯកសារសេចក្តីព្រាងផែនការសកម្មភាពអនុតំបន់ លើកទី៨ ដែលបានរៀបចំ ពិនិត្យ និងពិភាក្សានៅក្នុងកិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ ។

៤- សិក្ខាសាលាស្តីពីការអង្កេតការរត់ពន្ធទេសន្តប្រវេសន៍ កាលពីថ្ងៃទី១២ខែឧសភាឆ្នាំ២០១១ នៅប្រទេសវៀតណាម ក្នុងគោលបំណងសំខាន់គឺ ពង្រឹងសមត្ថភាពជំនាញដល់មន្ត្រីអនុវត្តច្បាប់ក្នុងតំបន់ អំពីការប្រយុទ្ធប្រឆាំងទៅនឹងឧក្រិដ្ឋកម្មឆ្លងដែនមានការចាត់តាំង (TOC. Transnational Organize Crime) ពិសេសការរត់ពន្ធទេសន្តប្រវេសន៍ តាមរយៈការបង្កើតកម្មវិធីបណ្តុះបណ្តាលជំនាញតាមប្រព័ន្ធកុំព្យូទ័រ (CBT. Computer Based Training) ។

៥- កិច្ចប្រជុំថ្នាក់ជាតិ នៃក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខ អាស៊ាន កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ នៅទីស្តីការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

ក្រៅពីការអនុវត្តយុទ្ធសាស្ត្រពហុវិស័យខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានយកចិត្តទុកដាក់ជំរុញលើការងារមួយចំនួនទៀត មានដូចជា :

- ការអនុវត្តន៍អនុសាសន៍ណែនាំ របស់ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តំណាងដ៏ខ្ពង់ខ្ពស់ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានដាក់ចេញនៅក្នុងសន្និបាតបូកសរុបលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១០ និងទិសដៅការងារ ឆ្នាំ២០១១ កាលពីថ្ងៃទី៣១ ខែឧសភា ដល់ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០១១ ។
- ការរៀបចំយន្តការទប់ស្កាត់ការចរាចរគ្រឿងញៀនឆ្លងកាត់តាមបណ្តាខេត្តជាប់ព្រំដែន កម្ពុជា-ឡាវ ។
- កិច្ចសហការជាមួយអង្គការ KHANA ក្នុងការពង្រឹងសមត្ថភាពមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀនដើម្បីអាចបំពេញតួនាទី ភារកិច្ច របស់ខ្លួនកាន់តែមានប្រសិទ្ធភាព ជាពិសេស លើការងារគ្រប់គ្រងទិន្នន័យព័ត៌មានគ្រឿងញៀនតាមលក្ខណៈវិទ្យាសាស្ត្រ ។

## III. ការសន្និដ្ឋាន និង វាយតម្លៃ

ក្នុងខែមិថុនានេះ ដោយមានកិច្ចសហការល្អពីក្រសួងសមាជិក ក្រសួង-ស្ថាប័នពាក់ព័ន្ធនានា និងកម្លាំងសរុបរបស់សង្គម អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តអនុវត្តយុទ្ធសាស្ត្រពហុវិស័យស្តីពីការត្រួតពិនិត្យគ្រឿងញៀនទទួលបានលទ្ធផលល្អប្រសើរ ក្នុងនោះ ៖

លើការងារលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀននិងអេដស៍ បានពិនិត្យឃើញមានការចូលរួមយ៉ាងផុលផុសពីគ្រប់មជ្ឈដ្ឋានសង្គម ជាពិសេស គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត តាមរយៈ ការប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ញ៉ាំងឱ្យការផ្សព្វផ្សាយអប់រំក្នុងខែមិថុនាមានសកម្មភាពលេចធ្លោគួរឱ្យកត់សំគាល់ ។ ប៉ុន្តែយើងក៏បានរកឃើញនូវចំណុចអវិជ្ជមានមួយចំនួនផងដែរ ដែលផ្តើមចេញពីការប្រារព្ធទិវានេះ ដោយសារថា អ្នកដែលចូលរួមប្រារព្ធទិវាភាគច្រើនជាអ្នករស់នៅទីប្រជុំជនដែលសុទ្ធសឹងជាបញ្ញាវន្ត ឯក្រុមគោលដៅដែលងាយប្រឈមខ្ពស់នឹងគ្រោះថ្នាក់ ឬអ្នករស់នៅតាមតំបន់ដាច់ស្រយាលមួយចំនួន នៅតែមិនទាន់ទទួលបានការអប់រំទូលំទូលាយនៅឡើយ ។

ការអនុវត្តច្បាប់ ក៏ពិនិត្យឃើញមន្ត្រីអនុវត្តច្បាប់គ្រប់សមាសភាព និងគ្រប់លំដាប់ថ្នាក់បានខិតខំប្រឹងប្រែងក្នុងការបង្ក្រាបបទល្មើសគ្រឿងញៀនទទួលបានលទ្ធផលគួរកត់សំគាល់ ។ ប៉ុន្តែអាស្រ័យដោយការរីកចម្រើនខាងផ្នែកបច្ចេកវិទ្យា ការរីកចម្រើន

ខាងផ្នែកសេវាកម្មដឹកជញ្ជូនរហ័សតាមផ្លូវអាកាស គួបផ្សំនឹងសមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់នៅមានកម្រិត បានបង្កលក្ខណៈឱ្យពួកឈ្មួញគ្រឿងញៀនមានឱកាសលបលួចធ្វើការផលិត ចរាចរ ជួញដូរចែកចាយ នាំឆ្លងកាត់ ពង្រីកបណ្តាញទាក់ទង និងពង្រីកទីផ្សារគ្រឿងញៀន ។

ការព្យាបាល/ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ក្រសួងសុខាភិបាលក៏បានពង្រឹងសមត្ថភាពក្នុងការផ្តល់សេវាថែទាំ និងព្យាបាលតាមបែបវេជ្ជសាស្ត្រដល់មណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ ធ្វើឱ្យកាន់តែមានភាពសមស្របនិងល្អប្រសើរជាងមុន ។ ដោយឡែក ការអនុវត្តនីសាកល្បងនូវកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមសហគមន៍នៅខេត្តបន្ទាយមានជ័យ ក៏ទទួលបានលទ្ធផលល្អគួរកត់សំគាល់ ដែលអាចរំពឹងបានថា ទៅថ្ងៃមុខនឹងមានការរីកចម្រើនជាងនេះ ។ ប៉ុន្តែយើងក៏បានកត់សំគាល់ឃើញផងដែរថា ការពង្រីកកម្មវិធីព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍នៅមានភាពយឺតយ៉ាវ និងមិនទាន់អនុវត្តបានទូលំទូលាយនៅតាមតំបន់គោលដៅនៅឡើយ ។

ចំពោះកិច្ចសហប្រតិបត្តិការអន្តរជាតិ យើងក៏បានខិតខំពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាលក្ខណៈ ទ្វេភាគី និង ពហុភាគី បានច្រើនជាមួយបណ្តាអង្គការ និងប្រទេសជាដៃគូអភិវឌ្ឍន៍ ។ ប៉ុន្តែយើងនៅមិនទាន់ទទួលបាននូវលទ្ធផលមកវិញឱ្យបានពេញលេញពីបណ្តាគម្រោងទាំងអស់នោះនៅឡើយ ។

## IV. ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែ កក្កដា ឆ្នាំ២០១១

ដូចបានធ្វើការសន្និដ្ឋាននិងវាយតម្លៃអំពីសភាពការណ៍គ្រឿងញៀន និងចំណុចប្រឈមក្នុងការអនុវត្តយុទ្ធសាស្ត្រពហុ-វិស័យទាំង៥ ខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានដាក់ចេញនូវទិសដៅសម្រាប់អនុវត្តបន្តដូចខាងក្រោម :

១. ត្រៀមចូលរួមទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន"២៦ មិថុនា ២០១១" នៅខេត្តកំពង់ចាម ដែលនឹងត្រូវប្រារព្ធនៅថ្ងៃទី ០៦/៧/២០១១ ។

២. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តកិច្ចសហការ សម្របសម្រួលជាមួយក្រសួងជាសមាជិក និងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា, គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ជារួមគឺកម្លាំងសរុបរបស់សង្គម ដើម្បីអនុវត្តការផ្សព្វផ្សាយអប់រំ លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីច្បាប់និងគ្រោះថ្នាក់នៃគ្រឿងញៀន និងការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍ តាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និង ឯកជន តាមគ្រប់វិធានការដែលអាចធ្វើទៅបាន ។

៣. ត្រៀមលក្ខណៈសម្បត្តិ ចុះធ្វើសកម្មភាពផ្សព្វផ្សាយអប់រំពីផលវិបាកនៃគ្រឿងញៀន នៅអនុវិទ្យាល័យចតុមុខ, វិទ្យាល័យព្រះស៊ីសុវត្ថិ, វិទ្យាល័យបាក់ទូក, វិទ្យាល័យទួលស្វាយព្រៃ, វិទ្យាល័យសន្ធរម៉ុក, វិទ្យាល័យវត្តកោះ, វិទ្យាល័យជម្ពូវ័ន, វិទ្យាល័យសាមគ្គី និង វិទ្យាល័យព្រែកលាប ។

៤. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងធ្វើការបូកសរុប ដើម្បីរៀបចំកិច្ចប្រជុំពិភាក្សាអំពីលទ្ធផលបឋមពាក់ព័ន្ធនឹងដំណើរការចុះសិក្សាស្រាវជ្រាវ ប្រមែប្រមូលទិន្នន័យព័ត៌មានពាក់ព័ន្ធនឹងការគ្រប់គ្រង ការចរាចរ និងការប្រើប្រាស់សារធាតុគីមីផ្សំ នៅខេត្តស្វាយរៀង ។

៥. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តប្រមូលទិន្នន័យ ស្តីពីការនាំចូល-ការនាំចេញ និងការប្រើប្រាស់សារ-

ធាតុគីមីផ្សំគ្រឿងញៀន ។

៦. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រៀមចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយលទ្ធផលអង្កេតឈាមរកអត្រាផ្ទុកមេរោគអេដស៍នៅកម្ពុជា ឆ្នាំ២០១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៤ខែកក្កដាឆ្នាំ២០១១ នៅសណ្ឋាគារសាន់វ៉េ ដែលរៀបចំដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគនៃក្រសួងសុខាភិបាល ។

៧. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រៀមរៀបចំឯកសារនានា ដែលពាក់ព័ន្ធនឹងមណ្ឌលបណ្ដោះអាសន្នសម្រាប់អប់រំ ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ជូនរដ្ឋសភាសម្រាប់បំភ្លឺជូនអង្គការមូលនិធិពិភពលោក ដែលបានហៅមណ្ឌលបណ្ដោះអាសន្នរបស់រដ្ឋ ថាជា "មណ្ឌលឃុំឃាំង" ។

៨. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តសហការ សម្របសម្រួលជាមួយក្រសួងសុខាភិបាល និងក្រសួងពាក់ពន្ធ័នានា ជំរុញការរៀបចំសេវាព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមសហគមន៍ ។

៩. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តជំរុញខេត្តបន្ទាយមានជ័យឱ្យបន្តការអនុវត្តន៍ ផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀន និងជំរុញរាជធានី-ខេត្តដទៃទៀត ឱ្យរៀបចំផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀន ។

១០. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រៀមចាត់តាំងមន្ត្រីមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន ចំនួន ២ រូប ទៅចូលរួមសិក្ខាសាលាថ្នាក់តំបន់ ស្តីពី Global Smart ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី១៨-២០ ខែកក្កដា ឆ្នាំ២០១១ នៅទីក្រុងបាងកក ប្រទេសថៃ ។

១១. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តធ្វើការកែសម្រួលនិងពង្រឹងរចនាសម្ព័ន្ធ យន្តការការងាររបស់ការិយាល័យទំនាក់ទំនងព្រំដែន(BLO)ទាំង១៤កន្លែង តាមអនុសាសន៍ណែនាំរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ។

១២. អ.ជ.ប.គ.ញ នឹងត្រៀមរៀបចំដំណើរទស្សនកិច្ចរបស់គណៈប្រតិភូជាន់ខ្ពស់ អ.ជ.ប.គ.ញ ដែលដឹកនាំដោយឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ទៅកាន់ប្រទេសឡាវ ពីថ្ងៃទី ២៥-២៨ ខែកក្កដា ឆ្នាំ២០១១ ។

១៣. អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ត្រៀមចាត់តាំងមន្ត្រីជំនាញ និងសម្របសម្រួលជាមួយក្រសួងពាក់ពន្ធ័ ដើម្បីចាត់តាំងមន្ត្រីជំនាញរបស់ខ្លួន ទៅចូលរួមក្នុងសិក្ខាសាលាតំបន់ ស្តីពីការបង្ការការប្រើប្រាស់សារធាតុញៀន និងផលវិបាករបស់គ្រឿងញៀន ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ០៥-០៨ ខែ កក្កដា ឆ្នាំ ២០១១ នៅទីក្រុងហូជីមិញ ប្រទេស វៀតណាម ។

១៤. ត្រៀមចាត់បញ្ជូនមន្ត្រីអនុវត្តច្បាប់ (នគរបាលជាតិ-កងរាជអាវុធហត្ថ) ចំនួន ៣០ រូប ទៅបណ្ដុះបណ្ដាលការអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន នៅទីក្រុងគួនមិញ ខេត្តយូណាន់ ប្រទេសចិន នៅថ្ងៃទី១៨ ដល់ ២៨ ខែ កក្កដា ឆ្នាំ ២០១១ ។

ក្រៅពីទិសដៅជាយុទ្ធសាស្ត្រពហុវិស័យខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នឹងបន្តយកចិត្តទុកដាក់លើការងារមួយចំនួនទៀត ដូចខាងក្រោម :

- បន្តអនុវត្តអនុសាសន៍ណែនាំរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ ដែលបានលើកឡើងនៅក្នុងកិច្ច

ប្រជុំបូកសរុបលទ្ធផល និងដកពិសោធន៍ការអនុវត្តន៍ផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀនខេត្តបន្ទាយមានជ័យ ។

- សហការ សម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ជំរុញការរៀបចំបង្កើតគណៈកម្មការចម្រុះ ដើម្បីចុះជួយការងារអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀននៅបណ្តាខេត្តតាមព្រំដែនភាគឦសានប្រទេស ។
- បន្តការរៀបចំយន្តការបង្កើត "សាលារៀនពណ៌បៃតង គ្មានគ្រឿងញៀន" ។
- បន្តការរៀបចំផែនការជាតិ៥ឆ្នាំ (២០១១-២០១៥) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។
- បន្តកិច្ចសហការជាមួយក្រសួងផែនការ ជំរុញការរៀបចំប្រព័ន្ធទិន្នន័យព័ត៌មានគ្រឿងញៀនថ្នាក់ជាតិ ។
- បន្តអនុវត្តការប៉ាន់ប្រមាណពីចំនួនអ្នកប្រើគ្រឿងញៀននៅកម្ពុជា ។/.

**អគ្គលេខាធិការ**

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អជបគញ

-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន

"ដើម្បីជូនជ្រាប"

-ក្រសួង សមាជិក អជបគញ

-ក្រសួងផែនការ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត

-នាយកដ្ឋាន សរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីមុខការ"

-ឯកសារ

# ការងារផ្សព្វផ្សាយអប់រំអំពី
# ច្បាប់ និង គ្រោះថ្នាក់នៃគ្រឿងញៀន ខែមិថុនា ឆ្នាំ២០១១

| ឈ្មោះ<br>អង្គភាពសាមី | ឈ្មោះអង្គភាព<br>សហការសំរបសំរួល | ខ្លឹមសារផ្សព្វផ្សាយ គោលដៅ សមាសភាព | ចំនួនអ្នក<br>ចូលរួម |
|---|---|---|---|
| អ.ជ.ប.គ.ញ | | -ការចូលរួមជាវាគ្មិន ក្នុងវគ្គបណ្តុះបណ្តាលស្តីពីផលប៉ះពាល់នៃគ្រឿងញៀន នៅវិទ្យាល័យ ជា ស៊ីម កំចាយមារ ខេត្តព្រៃវែង (បុគ្គលិក មន្ត្រីរាជការ សិស្ស ចូលរួម ៣៥០ នាក់)<br>-ការចូលរួមធ្វើបទឧទ្ទេសនាម នៅក្នុងសិក្ខាសាលាស្តីពី សភាពការណ៍ និងផលប៉ះពាល់ផ្សេងៗនៃឥទ្ធិពលគ្រឿងញៀនដល់សង្គមជាតិទាំងមូល នៅសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (និស្សិតថ្នាក់បរិញ្ញាបត្រ ចំនួន ៣០០ នាក់)<br>-ការចូលរួមឧទ្ទេសនាម ក្នុងវគ្គផ្សព្វផ្សាយឲ្យមានការយល់ដឹងពីផលប៉ះពាល់នៃគ្រឿងញៀន នៅខេត្តស្វាយរៀង (មានអ្នកចូលរួម ១៤៤ នាក់)<br>-ការផ្តល់ឯកសារផ្សព្វផ្សាយអប់រំ ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>-ការចូលរួមជាវាគ្មិន ក្នុងកម្មវិធី សមធម៌ នៃទូរទស្សន៍ជាតិកម្ពុជា ក្រោមប្រធានបទស្តីពី ការឆ្លុះបញ្ចាំងពីមេរៀនជាបទពិសោធន៍ លើការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ក្នុងចំណោមអ្នកប្រើគ្រឿងញៀន (មិនអាចក្តាប់បានចំនួន)<br>-ការផ្តល់បទសម្ភាស ក្រោមប្រធានបទស្តីពី ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងកម្មវិធី អរុណសួស្តី នៃទូរទស្សន៍ជាតិកម្ពុជា (មិនអាចក្តាប់បានចំនួន)<br>-ការអញ្ជើញចូលរួមជាអធិបតី និងជាកិត្តិយស នៅក្នុងពិធីអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅរាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ កំពង់ចាម ស្ទឹងត្រែង សៀមរាប ព្រះសីហនុ (ចំនួនមាននៅក្នុងតួលេខរួមទូទាំងប្រទេស) | ៧៩៤ នាក់ |
| ក្រសួងសង្គមកិច្ច | អ.ជ.ប.គ.ញ | -ការផ្តល់កិច្ចសម្ភាសនៅស្ថានីយទូរទស្សន៍ ស៊ី.ធី.អិន អ៊ីនធឺណេត ស្តីពីការទទួលខុសត្រូវរបស់ក្រសួងសង្គមកិច្ច ក្នុងការផ្សព្វផ្សាយអប់រំ កែប្រែ និង ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន<br>-ការចុះធ្វើសកម្មភាពផ្សព្វផ្សាយអប់រំ ទប់ស្កាត់ដល់កុមារ និងយុវជននៅតាមសាលារៀន និងសហគមន៍ (អ្នកចូលរួមសរុបចំនួន ៥០០ នាក់) | ៥០០ នាក់ |
| ក្រសួងព័ត៌មាន | អ.ជ.ប.គ.ញ | -ការជំរុញឲ្យបណ្តាញផ្សព្វផ្សាយព័ត៌មានទាំងអស់ ជួយផ្សព្វផ្សាយសារលិខិត របស់សម្តេចនាយករដ្ឋមន្ត្រី ផ្ញើជូនបងប្អូនជនរួមជាតិ ក្នុងឱកាសអបអរសាទរទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | |
| ក្រសួងទេចរណ៍ | អ.ជ.ប.គ.ញ | -ផលិតខិត្តបណ្ណ័ផ្សព្វផ្សាយពី គ្រឿងញៀន អេដស៍ ការជួញដូរកេទ និង ការជួញដូរអាវុធជាតិផ្ទុះ | |
| ភ្នំពេញ | | -ប្រារព្ធពិធីអបអរសាទរទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ ០៦ ២០១១<br>**-ដុត ហេរ៉ូអ៊ីន ១២,៣៦២ គ.ក្រ មេតំហ្វេតាមីន ៤០.៤៦៨ គ្រាប់ មេតំហ្វេតាមីន អាយ ៤,៧៥១ គ.ក្រ ថ្នាំញៀនចម្រុះ ៥៨.៥៤៤ គ្រាប់ ម្សៅកេតាមីន ០,៣១ ក្រាម កញ្ឆាក្រៀម ២៦៤,៧២ ក្រាម អ៊ិចស្តាស៊ី ២៩,៩៩ ក្រាម សារជាតុគីមី ៤.៧២៦ គ.ក្រ** | ៤.១២៩ នាក់ |
| ខេត្តបាត់ដំបង | អាជ្ញាធរខេត្ត | -ពិធីអបអរសាទរ ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ មិថុនា ២០១១ **និងដុតមេតំហ្វេតា-មីន ២៦.៩៩៨ គ្រាប់ មេតំហ្វេតាមីន អាយ ២៤,៣៧ ក្រាម ហេរ៉ូអ៊ីន ៧០៦,០៦ ក្រាម** | ៣.៦៧៥ នាក់ |
| | ន.ប ឃុំជ្រៃ | -បញ្ជ្រាបការងារផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន និងមេរោគអេដស៍ នៅក្នុងពិធីផ្សព្វផ្សាយគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព (អ្នកចូលរួម ១០៣២ នាក់ / ស្រី ៥១២ នាក់) | ១.០៣២ នាក់ |
| ខេត្តកំពង់ធំ | អាជ្ញាធរខេត្ត | -ផ្សព្វផ្សាយច្បាប់ និងផលប៉ះពាល់នៃគ្រឿងញៀន ចំនួន ១០ លើក / លើ ១១ ឃុំ នៃស្រុកបារាយណ៍ ស្រុកស្ទោង ស្រុកប្រាសាទបល្ល័ង្គ (មានអ្នកចូល រួមចំនួន ៤០៨៩ នាក់ / ស្រី ១៧៧៣ នាក់) | ៤.០៨៩ នាក់ |
| | តំបន់ប្រតិបត្តិការសឹករងកំពង់ធំ | -ផ្សព្វផ្សាយគ្រោះថ្នាក់នៃគ្រឿងញៀន ដល់នាយទាហាន ៤លើក= (១៨៦ នាក់ / ស្រី៤ នាក់) | ១៨៦ នាក់ |
| | អាជ្ញាធរខេត្ត | -ប្រារព្ធពិធីអបអរសាទរទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ ០៦ ២០១១ | ៤៦២ នាក់ |
| ខេត្តក្រចេះ | អាជ្ញាធរខេត្ត | -ផ្សព្វផ្សាយអប់រំ ពីគ្រោះថ្នាក់នៃគ្រឿងញៀន ដល់មុខសញ្ញាងាយរងគ្រោះ ប្រជាពលរដ្ឋទូទៅតាមគ្រួសារ សហគមន៍ ក្មេងទំនើង ក្រុមជនបង្គោល ២៥ លើក (៣៣៧ នាក់ / ស្រី ១៦៥ នាក់) | ៣៣៧ នាក់ |
| | អាជ្ញាធរខេត្ត | -ប្រារព្ធពិធីអបអរសាទរទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ ០៦ ២០១១ | ៥០៩ នាក់ |
| ខេត្តប៉ៃលិន | អាជ្ញាធរខេត្ត | -ប្រារព្ធពិធីអបអរសាទរទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ ០៦ ២០១១<br>**-ដុតមេតំហ្វេតាមីន ៧.០៦៧ គ្រាប់** | ៨៩០ នាក់ |
| ខេត្តបន្ទាយមានជ័យ | អាជ្ញាធរខេត្ត | -ប្រារព្ធពិធីអបអរសាទរទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ ០៦ ២០១១<br>**-ដុតមេតំហ្វេតាមីន ១៧៦.៨១០ គ្រាប់ មេតំហ្វេតាមីន អាយ ១,៥៨៥ គ.ក្រ កញ្ឆាក្រៀម ៥ គ.ក្រ** | ១៣.១៨០ នាក់ |
| ខេត្តកែប | អាជ្ញាធរខេត្ត | -ប្រារព្ធពិធីអបអរសាទរទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ ០៦ ២០១១ | ៥៨៦ នាក់ |
| ខេត្តកោះកុង | អាជ្ញាធរខេត្ត | -ប្រារព្ធពិធីអបអរសាទរទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ ០៦ ២០១១ | ៣៥០ នាក់ |

| | | | |
|---|---|---|---|
| ខេត្តព្រៃវែង | ស្រុក-ក្រុង ១៣ | -ប្រារព្ធពិធីអបអរសាទរទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ ០៦ ២០១១ | ៩.៧១១ នាក់ |
| ខេត្តរតនគីរី | អាជ្ញាធរខេត្ត | -ប្រារព្ធពិធីអបអរសាទរទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ ០៦ ២០១១ | ៥៣១ នាក់ |
| ខេត្តកណ្តាល | អាជ្ញាធរខេត្ត | -ប្រារព្ធពិធីអបអរសាទរទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ ០៦ ២០១១ | ១.០៤១ នាក់ |
| ខេត្តកំពង់ស្ពឺ | អាជ្ញាធរខេត្ត | -ប្រារព្ធពិធីអបអរសាទរទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ ០៦ ២០១១ | ១.២២៦ នាក់ |
| ខេត្តតាកែវ | អាជ្ញាធរខេត្ត | -ប្រារព្ធពិធីអបអរសាទរទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ ០៦ ២០១១ | ៤៣២ នាក់ |
| ខេត្តព្រះសីហនុ | អាជ្ញាធរខេត្ត | -ប្រារព្ធពិធីអបអរសាទរទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ ០៦ ២០១១ | ១.១១៣ នាក់ |
| ខេត្តស្ទឹងត្រែង | អាជ្ញាធរខេត្ត | -ប្រារព្ធពិធីអបអរសាទរទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ ០៦ ២០១១ | ១.១៩២ នាក់ |
| ខេត្តកំពត | អាជ្ញាធរខេត្ត | -ប្រារព្ធពិធីអបអរសាទរទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ ០៦ ២០១១ | ២៥៦១ នាក់ |
| ខេត្តព្រះវិហារ | អាជ្ញាធរខេត្ត | -ផ្សព្វផ្សាយច្បាប់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ៣លើក នៅស្រុករវៀង (មានអ្នកចូលរួមចំនួន ២៣៤ នាក់ / ស្រី ១២៩ នាក់) | ២៣៤ នាក់ |
| | អាជ្ញាធរខេត្ត | -ប្រារព្ធពិធីអបអរសាទរទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ ០៦ ២០១១ | ៦០០ នាក់ |
| ខេត្តសៀមរាប | អាជ្ញាធរខេត្ត | -ប្រារព្ធពិធីអបអរសាទរទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ ០៦ ២០១១ | ១.៣៤០ នាក់ |
| ខេត្តកំពង់ឆ្នាំង | អាជ្ញាធរខេត្ត | -ប្រារព្ធពិធីអបអរសាទរទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ ០៦ ២០១១ | ៥២២ នាក់ |
| ខេត្តកំពង់ចាម | អាជ្ញាធរខេត្ត | -ប្រារព្ធពិធីអបអរសាទរទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ ០៦ ២០១១<br>**-ដុត មេតំហ្វេតាមីន ២.០២៦ គ្រាប់ មេតំហ្វេតាមីន អាយ ១៨,៣ ក្រាម** | ១.៦៨៧ នាក់ |
| ខេត្តឧត្តរមានជ័យ | អាជ្ញាធរខេត្ត | -ប្រារព្ធពិធីអបអរសាទរទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ ០៦ ២០១១ | ១.៥១៦ នាក់ |
| ខេត្តមណ្ឌលគីរី | អាជ្ញាធរខេត្ត | -ប្រារព្ធពិធីអបអរសាទរទិវាប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ ០៦ ២០១១ | ១២០ នាក់ |
| ខេត្តស្វាយរៀង | ស្រុក ក្រុង មន្ទីរ | -ណែនាំឲ្យចងបដា ពាក្យស្លោក មិនបានប្រារព្ធទិវាអបអរសាទរ ទេ | |
| | | **សរុប** | ៥៤.៥៤៥ នាក់ |

## អង្គភាពបង្ក្រាបបទល្មើសគ្រឿងញៀន ខែមិថុនា ឆ្នាំ២០១១

| លរ | អង្គភាពបង្ក្រាប | សរុបរួម | | | ផលិត | | | ចរាចរជួញដូរចែកចាយ | | | ដាំដុះ ចម្រាញ់ប្រែងរុក្ខ. | | | ប្រើប្រាស់គ្រឿងញៀន | | | ចាប់តាមដីកា | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី | ករណី | នាក់ | ស្រី |
| 1 | មន្ទីរប្រឆាំង គ្រ.ញ | 2 | 2 | 1 | | | | 2 | 2 | 1 | | | | | | | | | |
| 2 | ន.ប ភ្នំពេញ | 22 | 58 | 11 | 1 | 5 | 2 | 20 | 52 | 9 | 1 | 1 | 0 | | | | | | |
| 3 | ន.ប កណ្ដាល | 8 | 19 | 3 | | | | 5 | 10 | 1 | | | | 3 | 9 | 2 | | | |
| 4 | ន.ប កំពង់ចាម | 4 | 13 | 1 | | | | 3 | 11 | 1 | | | | 1 | 1 | 0 | 0 | 1 | 0 |
| 5 | ន.ប ព្រះសីហនុ | 6 | 8 | 1 | | | | 6 | 8 | 1 | | | | | | | | | |
| 6 | ន.ប សៀមរាប | 3 | 9 | 3 | | | | 3 | 9 | 3 | | | | | | | | | |
| 7 | ន.ប ព្រះវិហារ | 1 | 2 | 0 | | | | 1 | 2 | 0 | | | | | | | | | |
| 8 | ន.ប បាត់ដំបង | 13 | 23 | 3 | | | | 12 | 22 | 3 | | | | 1 | 1 | 0 | | | |
| 9 | ន.ប បន្ទាយមានជ័យ | 14 | 22 | 6 | | | | 13 | 19 | 6 | | | | 1 | 3 | 0 | | | |
| 10 | ន.ប កែប | 1 | 1 | 0 | | | | | | | | | | 1 | 1 | 0 | | | |
| 11 | ន.ប ពោធិ៍សាត់ | 1 | 2 | 1 | | | | 1 | 2 | 1 | | | | | | | | | |
| 12 | ន.ប កំពង់ធំ | 2 | 3 | 0 | | | | 1 | 1 | 0 | | | | 1 | 2 | 0 | | | |
| 13 | ន.ប ឧត្តរមានជ័យ | 1 | 4 | 0 | | | | 1 | 4 | 0 | | | | | | | | | |
| 14 | ន.ប កំពង់ស្ពឺ | 1 | 3 | 0 | | | | | | | | | | 1 | 3 | 0 | | | |
| | **សរុប** | 79 | 169 | 30 | 1 | 5 | 2 | 68 | 142 | 26 | 1 | 1 | 0 | 9 | 20 | 2 | 0 | 1 | 0 |

## វត្ថុតាងចាប់យក ក្នុងខែមិថុនា ឆ្នាំ២០១១ (រាយតាមអង្គភាពប្រតិបត្តិការ)

| លរ | ឈ្មោះអង្គភាព | វត្ថុតាងចាប់យក | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ***WY*** (គ្រាប់) | ***ICE*** (ក្រាម) | ***Heroine*** (ក្រាម) | ដើមកញ្ឆា ម២ | កញ្ឆាក្រៀម (ក្រាម) | ***Ecstasy*** (គ្រាប់) | ***Pseudo-Ephedrine*** | កូកាអ៊ីន (ក្រាម) | ប្រេងម្រះព្រៅភ្នំ |
| ***1*** | មន្ទីរប្រឆាំងគ្រឿងញៀន | | *98,5* | | | | | | *267,7* | |
| ***2*** | ន.ប ភ្នំពេញ | *153* | *268,63* | *282,41* | *500* | *13,90* | | | | |
| ***3*** | ន.ប កណ្ដាល | | *0,58* | | | | | | | |
| ***4*** | ន.ប កំពង់ស្ពឺ | | *0,02* | | | | | | | |
| ***5*** | ន.ប កំពង់ចាម | | *2,4* | | | | | | | |
| ***6*** | ន.ប ព្រះសីហនុ | *46* | *0,94* | | | *47* | | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| *7* | ន.ប ស្ទឹងត្រែង | *30.162* | | | | | | | | |
| *8* | ន.ប ព្រះវិហារ | *3.920* | | | | | | | | |
| *9* | ន.ប បាត់ដំបង | *192* | *4,2* | | | | | | | |
| *10* | ន.ប បន្ទាយមានជ័យ | *8.724* | | | | *1* | | | | |
| *11* | ន.ប កែប | | | | | | | | | |
| *12* | ន.ប ពោធិ៍សាត់ | | *4,95* | | | | | | | |
| *13* | ន.ប កំពង់ធំ | | *1,2* | | | | | | | |
| *14* | ន.ប ឧត្តរមានជ័យ | | *1,35* | | | | | | | |
| | សរុប | ***43197*** | ***382,77*** | ***282,41*** | ***500*** | ***61,9*** | | | ***267,7*** | |

**វត្ថុតាងផ្សេងៗ៖**

1-មន្ទីរប្រឆាំង គ្រ.ញ — រថយន្ត ១គ្រឿង

2-ន.ប ភ្នំពេញ — សារធាតុគីមីផ្សំគ្រឿងញៀន ២៩.៥៩១,៨១ ក្រាម, ជញ្ជីង ៣, ដង្កៀ១, ពុម្ព១, កាំភ្លើងខ្លី ៣ ដើម, កាំភ្លើងវែង ១ ដើម, ដាវ ១ ដើម, រថយន្ត ២ គ្រឿង, ម៉ូតូ ១៤ គ្រឿង, លុយ ៦.៤២៥.១០០ រៀល, ១.០៤៣ ដុល្លារ, ១៤០ ដុល្លារសាំងហ្គាពួរ, ៤១០.០០០ ដុង, ១២៣ យន់, ឧបករណ៍ផលិតមួយចំនួន

3-ន.ប កណ្តាល — ម៉ូតូ ៣ គ្រឿង, ដាវ ២ ដើម

4-ន.ប កំពង់ស្ពឺ — ឧបករណ៍ប្រើប្រាស់មួយចំនួន

5-ន.ប កំពង់ចាម — ឧបករណ៍ប្រើប្រាស់មួយចំនួន

6-ន.ប ព្រះសីហនុ — ប្រេងកញ្ឆា កន្លះកែវ, ម៉ូតូ១គ្រឿង, លុយ ៦០ ដុល្លារ និង ២០.០០០ រៀល

7-ន.ប ពោធិ៍សាត់ — ៤,៩៥ ក្រាម, ឧបករណ៍វេចខ្ចប់ ប្រើប្រាស់មួយចំនួន, លុយ ៣.៣០២.០០០ រៀល និង ២០ បាត

8-ន.ប បាត់ដំបង — WY ៤,១ ក្រាម, ម៉ូតូ ២ គ្រឿង, កាំភ្លើងខ្លី ១ ដើម, កាំភ្លើងវែង ២ ដើម, លុយ ៤៣.៨០០ រៀល និង ៦០ បាត

9-ន.ប កំពង់ធំ — ឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន

10-ន.ប បន្ទាយមានជ័យ — ម៉ូតូ ២ គ្រឿង

11-ន.ប កែប — ឧបករណ៍ប្រើប្រាស់គ្រឿងញៀនមួយចំនួន

12-ន.ប ឧត្តរមានជ័យ — លុយ ៦៧៦.០០០ រៀល និង ១៥១ ដុល្លារ

## ទិន្នន័យសារធាតុគីមីផ្សំមានអាជ្ញាប័ណ្ណនាំចូល ប្រចាំខែ មិថុនា ឆ្នាំ ២០១១

| *ឈ្មោះសារធាតុគីមី* | *អាជ្ញាបណ្ណ័ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល* | | | *អាជ្ញាបណ្ណ័ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា* | | | *សរុប* | | |
|---|---|---|---|---|---|---|---|---|---|
| | Kg | L | Amp | Kg | L | Amp | Kg | L | Amp |
| Methylene Chloride | | | | 144.760 | | | **144.760** | | |
| Toluene | | | | 28.290 | | | **28.290** | | |
| Formic Acid | | | | 1.500 | | | **1.500** | | |
| Ethyl Acetate | | | | 22.000 | | | **22.000** | | |
| Acetone | | | | 20.000 | | | **20.000** | | |
| Acide Acetic | | | | 75.000 | | | **75.000** | | |
| Caustic Soda | | | | 67.600 | | | **67.600** | | |
| Soda Ash | | | | 340.000 | | | **340.000** | | |
| Solvant | 100.000 | | | | | | **100.000** | | |
| សរុប | **100.000** | | | **699.150** | | | **799.150** | | |